**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

លេខ : ៤៥៤/២៤ មស.សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការរៀបចំធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធ និងទិន្នន័យមន្ត្រីក្នុងវិស័យសុខាភិបាល

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៣/២១៤២ ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងវិស័យសុខាភិបាល របស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៣/២១៤៣ ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ របស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា
- បានឃើញអនុក្រឹត្យលេខ ៣០៩ អនក្រ.បក ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣ ស្តីពីតួនាទីនិងភារកិច្ចរបស់ក្រសួងមុខងារសាធារណៈ ក្នុងក្របខណ្ឌជាលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា
- យោងតាមការចាំបាច់



ផ្លូវវិថីអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh

## សម្រេច

**ប្រការ១.-**

បង្កើតគណៈកម្មការរៀបចំធ្វើបច្ចុប្បន្នភាពចេនាសម្ព័ន្ធ និងទិន្នន័យមន្ត្រីក្នុងវិស័យសុខាភិបាល ដើម្បីគាំទ្រដល់ការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង និងប្រើប្រាស់ធនធានមនុស្សនៅតាមអង្គភាពសុខាភិបាលមូលដ្ឋានរួមមាន ប៉ុស្តិ៍សុខភាព មណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែកផ្តល់សេវាសំណុំសកម្មភាពបង្គ្រប់កម្រិត១ និងមន្ទីរពេទ្យបង្អែកផ្តល់សេវាសំណុំសកម្មភាពបង្គ្រប់កម្រិត២ ដែលមានសមាសភាពដូចខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១- | ឯកឧត្តម | **ហ៊ុន ម៉ានី** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមុខងារសារណៈ | ប្រធាន |
| ២- | ឯកឧត្តម | **យក់ ប៊ុនណា** | រដ្ឋលេខាធិការប្រចាំការ នៃក្រសួងមុខងារសាធារណៈ | អនុប្រធានប្រចាំការ |
| ៣- | ឯកឧត្តម | **មី សំបូរ** | រដ្ឋលេខាធិការប្រចាំការ នៃក្រសួងសុខាភិបាល | អនុប្រធាន |
| ៤- | ឯកឧត្តម | **ចាន់ សុធី** | រដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៥- | ឯកឧត្តម | **ចាន់ សុធា** | រដ្ឋលេខាធិការ នៃក្រសួងមហាផ្ទៃ និងជាអនុប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប. | អនុប្រធាន |
| ៦- | ឯកឧត្តម | **រស់ សូផាន់** | រដ្ឋលេខាធិការ នៃក្រសួងមុខងារសាធារណៈ | សមាជិក |
| ៧- | ឯកឧត្តម | **ថោ សេដ្ឋាណា** | រដ្ឋលេខាធិការ នៃក្រសួងមុខងារសាធារណៈ | សមាជិក |
| ៨- | ឯកឧត្តម | **ដុក មុន្នី** | រដ្ឋលេខាធិការ នៃក្រសួងមុខងារសាធារណៈ | សមាជិក |
| ៩- | ឯកឧត្តម | **ជ្រឿ សុខលាង** | រដ្ឋលេខាធិការ នៃក្រសួងមុខងារសាធារណៈ | សមាជិក |
| ១០- | ឯកឧត្តម | **ស សាម៉ុឌី** | រដ្ឋលេខាធិការ នៃក្រសួងមុខងារសាធារណៈ | សមាជិក |
| ១១- | ឯកឧត្តម | **សំ រិទ្ធី** | រដ្ឋលេខាធិការ នៃក្រសួងមុខងារសាធារណៈ | សមាជិក |
| ១២- | ឯកឧត្តម | **សុខ សប្បាយណា** | រដ្ឋលេខាធិការ នៃក្រសួងមុខងារសាធារណៈ | សមាជិក |
| ១៣- | ឯកឧត្តម | **សុខ សទ្វារ** | រដ្ឋលេខាធិការ នៃក្រសួងមុខងារសាធារណៈ | សមាជិក |
| ១៤- | ឯកឧត្តម | **ឈួរ សុបញ្ញា** | រដ្ឋលេខាធិការ នៃក្រសួងមុខងារសាធារណៈ | សមាជិក |
| ១៥- | ឯកឧត្តម | **គង់ សុភី** | ប្រធានក្រុមការងារបច្ចេកទេសកែលម្អប្រព័ន្ធជ្រើសរើសមន្ត្រីនៃអនុគណៈកម្មាធិការប្រតិបត្តិ នៃ គ.វ.រ. | សមាជិក |
| ១៦- | លោកជំទាវ | **ឈី វិជ្ជរ៉ា** | ប្រធានក្រុមការងារបច្ចេកទេសលើកកម្ពស់ប្រសិទ្ធភាពការងារនៃអនុគណៈកម្មាធិការប្រតិបត្តិ នៃ គ.វ.រ. | សមាជិក |
| ១៧- | ឯកឧត្តម | **ឆាយ ឆត្រាឧុធ** | ប្រធានក្រុមការងារបច្ចេកទេសកែលម្អប្រព័ន្ធលើកទឹកចិត្តផ្អែកលើសមិទ្ធកម្ម នៃអនុគណៈកម្មាធិការប្រតិបត្តិ នៃ គ.វ.រ. | សមាជិក |
| ១៨- | ឯកឧត្តម | **សោម គន្ធា** | អនុរដ្ឋលេខាធិការ នៃទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១៩- | ឯកឧត្តម | **នូច សុខសម្បត្តិ** | អនុរដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ២០- | ឯកឧត្តម | **ហេង ពិសាល** | អនុរដ្ឋលេខាធិការ នៃក្រសួងមុខងារសាធារណៈ | សមាជិក |
| ២១- | ឯកឧត្តម | **ឌី ហ្សានិត** | អនុរដ្ឋលេខាធិការ នៃក្រសួងមុខងារសាធារណៈ | សមាជិក |
| ២២- | ឯកឧត្តម | **យឿន សម្បត្តិ** | អនុរដ្ឋលេខាធិការ នៃក្រសួងមុខងារសាធារណៈ | សមាជិកអចិន្ត្រៃយ៍ |
| ២៣- | ឯកឧត្តម | **ឈុន សុជាតិ** | អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ក.ស. | សមាជិក |
| ២៤- | ឯកឧត្តម | **ពេជ្រ វិជ្ជាគន្ធី** | អគ្គនាយក នៃអគ្គនាយកដ្ឋានគ្រប់គ្រងមុខងារសាធារណៈ | សមាជិក |
| ២៥- | ឯកឧត្តម | **ឡុង សារឿន** | អគ្គនាយក នៃអគ្គនាយកដ្ឋានប្រព័ន្ធគ្រប់គ្រងមន្ត្រីតាមឌីជីថល | សមាជិក |
| ២៦- | ឯកឧត្តម | **ប្រាក់ ម៉ូច** | អគ្គនាយក នៃអគ្គនាយកដ្ឋានគោលនយោបាយមុខងារសាធារណៈ | សមាជិក |
| ២៧- | ឯកឧត្តម | **សយ រាសី** | អគ្គាធិការ នៃអគ្គាធិការដ្ឋានមុខងារសាធារណៈ | សមាជិក។ |

គណៈកម្មការ អាចមានសមាសភាពបន្ថែមជាអនុប្រធាន ឬ សមាជិក ដែលជាតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀតតាមការចាំបាច់។

**ប្រការ២.-**

គណៈកម្មការរៀបចំធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធ និងទិន្នន័យមន្ត្រីក្នុងវិស័យសុខាភិបាល មានភារកិច្ចដូចខាងក្រោម៖

- ដឹកនាំ សម្របសម្រួល និងគ្រប់គ្រងលើការធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធ និងទិន្នន័យមន្ត្រី នៅតាមប៉ុស្តិ៍សុខភាព មណ្ឌលសុខភាព មន្ទីរពេទ្យបង្អែកផ្តល់សេវាសំណុំសកម្មភាពបង្គ្រប់កម្រិត១ និងមន្ទីរពេទ្យបង្អែកផ្តល់សេវាសំណុំសកម្មភាពបង្គ្រប់កម្រិត២
- ដឹកនាំ និងសម្របសម្រួលការរៀបចំថ្នាលទិន្នន័យ និងធ្វើសមាហរណកម្មទិន្នន័យជាមួយប្រព័ន្ធទិន្នន័យផ្សេងទៀតរបស់រាជរដ្ឋាភិបាល និងក្រសួង ស្ថាប័នផ្អែកលើការចាំបាច់
- រៀបចំរបាយការណ៍បូកសរុបលទ្ធផលនៃការអនុវត្តការធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធ និងទិន្នន័យមន្ត្រី ដើម្បីប្រើប្រាស់សម្រាប់ការរៀបចំផែនការជ្រើសរើសមន្ត្រី កម្មវិធីពង្រាយមន្ត្រី និងកម្មវិធីអភិវឌ្ឍសមត្ថភាពមន្ត្រី
- អនុវត្តភារកិច្ចផ្សេងទៀតតាមការចាំបាច់ ដើម្បីគាំទ្រដល់ការធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធ និងទិន្នន័យមន្ត្រីក្នុងវិស័យសុខាភិបាល។

**ប្រការ៣.-**

អនុប្រធានប្រចាំការ អនុប្រធាន សមាជិក និងសមាជិកអចិន្ត្រៃយ៍នៃគណៈកម្មការរៀបចំធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធ និងទិន្នន័យមន្ត្រីក្នុងវិស័យសុខាភិបាល ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬ អនុប្រធានតាមការប្រគល់សិទ្ធិពីប្រធាន។

**ប្រការ៤.-**

គណៈកម្មការរៀបចំធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធ និងទិន្នន័យមន្ត្រីក្នុងវិស័យសុខាភិបាលអាចបង្កើតអនុគណៈកម្មការ និងក្រុមការងារផ្សេងទៀតតាមការចាំបាច់ ដើម្បីគាំទ្រការងារក្នុងការបំពេញភារកិច្ចដូចមានចែងក្នុងប្រការ២ ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងជាអនុប្រធានប្រចាំការនៃ **គ.ទ.រ.**។

**ប្រការ៥.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាននានា អគ្គាធិការនៃអគ្គាធិការដ្ឋាន នាយកសាលាភូមិន្ទរដ្ឋបាល ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងមុខងារសាធារណៈ និងក្រសួងស្ថាប័នពាក់ព័ន្ធ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១២កើត ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

**និងជាអនុប្រធានប្រចាំការ នៃ គ.ទ.រ.**

**ហ៊ុន ម៉ានី**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមហាផ្ទៃ
- ក្រសួងសុខាភិបាល
- រដ្ឋបាលរាជធានី ខេត្ត
- រដ្ឋបាលក្រុង ស្រុក ខណ្ឌ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
  "**ដើម្បីជូនជ្រាប**"
- ដូចប្រការ៥ "**ដើម្បីអនុវត្ត**"
- ឯកសារ កាលប្បវត្តិ